
www.kidsofdestiny.org

Kids of Destiny®
Reaching the Next Generation

# 1.06 កុមារភាពរបស់ព្រះយេស៊ូវ

អ្នកប្រហែលជាធ្លាប់ឮពីរឿង ដែលព្រះយេស៊ូវទ្រង់បានប្រសូតមក។ ទេវតាមួយរូបបានប្រាប់នាងម៉ារាថា នាងនឹងមានកូន ហើយទ្រង់នឹងក្លាយជាព្រះរាជបុត្រានៃព្រះ។ នាងនិងប្តីរបស់នាងគឺលោកយ៉ូសែបបានទៅភូមិបេថ្លេហិម ជាកន្លែងដែលព្រះយេស៊ូវទ្រង់ត្រូវប្រសូត។

ស្តេចហេរ៉ូឌបានដឹងអំពីរឿងនេះ។ គាត់ខ្លាចស្តេចថ្មីដែលទើបកាន់អំណាច ដូច្នេះគាត់ចង់ឲ្យគេសម្លាប់ព្រះយេស៊ូវ។ ប៉ុន្តែ ព្រះបានមានបន្ទូលប្រាប់យ៉ូសែបក្នុងសុបិន ហើយប្រាប់គាត់ឲ្យនាំក្រុមគ្រួសាររបស់គាត់ទៅនៅស្រុកអេស៊ីប។ នៅទីនោះពួកគេនឹងមានសុវត្ថិភាព។

វេលាកន្លងផុតទៅ។ ស្តេចហេរ៉ូឌបានសោយទិវង្គត។ ទេវតាមួយរូបបានមកប្រាប់យ៉ូសែបម្តងទៀត ឲ្យផ្លាស់ក្រុមគ្រួសាររបស់គាត់ទៅនៅក្រុងណាសារ៉ែតវិញ។ នោះគឺជាកន្លែងដែលព្រះយេស៊ូវបានធំធាត់ឡើង។ ទ្រង់មានភាពរឹងមាំខាងវិញ្ញាណ និងពោរពេញទៅដោយប្រាជ្ញា។ ព្រះអម្ចាស់គង់នៅជាមួយទ្រង់។

ជារៀងរាល់ឆ្នាំ មាតាបិតារបស់ព្រះយេស៊ូវបានទៅក្រុងយេរូសាឡិមដើម្បីធ្វើបុណ្យរំលង។ ការប្រារព្ធពិធីនេះ គឺដើម្បីចងចាំពីពេលវេលាដែលជនជាតិហេព្រើរត្រូវបានរំដោះពីស្តេចអាក្រក់នៅស្រុកអេស៊ីប ហើយនាំគ្នាទៅកាន់ទឹកដីថ្មី ដែលព្រះបានសន្យា។

ជារៀងរាល់ឆ្នាំមានមនុស្សយ៉ាងច្រើនបានទៅក្រុងយេរូសាឡិមសម្រាប់ពិធីពិសេសនេះ។ ពេលព្រះយេស៊ូវមានព្រះជន្មាយុដប់ពីរព្រះវស្សាព្រះអង្គបានយាងទៅក្រុងយេរូសាឡិមជាមួយមាតាបិតា ដើម្បីប្រារព្ធពិធីបុណ្យរំលង។ ត្រូវចំណាយពេលដើរជាច្រើនថ្ងៃដើម្បីទៅដល់។ ពួកគេបានធ្វើដំណើរជាមួយមនុស្សជាច្រើន។ វាពិតជាដំណើរដ៏រីករាយមួយ ទោះបីជាវាឆ្ងាយបន្តិចក៏ដោយ។

ថ្ងៃប្រារព្ធពិធីមកដល់ វាពិតជាធ្វើឲ្យមនុស្សគ្រប់គ្នារីករាយ។ លុះដល់ពេលត្រូវត្រលប់ទៅវិញ ព្រះយេស៊ូវក៏គង់នៅក្នុងក្រុងយេរូសាឡិមដដែល។ ដំបូង ម៉ារានិងយ៉ូសែបមិនបានព្រួយបារម្ភអំពីទ្រង់ឡើយ។ មានមនុស្សច្រើនណាស់ដែលធ្វើដំណើររួមជាមួយពួកគេ ដូច្នេះពួកគេគិតថាព្រះយេស៊ូវប្រហែលគង់នៅជាមួយមិត្តភក្តិ ឬសាច់ញាតិរបស់ទ្រង់។ ប៉ុន្តែបន្ទាប់ពីដើរប្រហែលមួយថ្ងៃ ពួកគេបានចាប់ផ្តើមស្វែងរកទ្រង់។ ពួកគេបានសួរមិត្តភក្តិរបស់ពួកគេ ប៉ុន្តែគ្មាននរណាម្នាក់បានឃើញទ្រង់ទេ។ ម៉ារានិងយ៉ូសែបចាប់ផ្តើមមានការព្រួយបារម្ភ។ ពួកគេបានត្រឡប់ទៅក្រុងយេរូសាឡិមវិញ ដើម្បីទៅរកព្រះយេស៊ូវ។

យ៉ូសែប និងម៉ារាបានរកមើលជុំវិញទីក្រុង។ ពួកគេច្បាស់ជាមានការព្រួយបារម្ភខ្លាំងណាស់។ ប៉ុន្តែបីថ្ងៃក្រោយមកពួកគេបានរកឃើញទ្រង់។ ព្រះយេស៊ូវគង់នៅក្នុងព្រះវិហារព្រះអង្គគង់នៅទីនោះជាមួយគ្រូជាច្រើន។ ទ្រង់កំពុងស្តាប់ពួកគេហើយសួរសំណួរ។ គ្រូទាំងអស់មានការងឿងឆ្ងល់ យ៉ាងខ្លាំងអំពីរបៀបដែលព្រះយេស៊ូវយល់ និងសំណួរដែលទ្រង់បានសួរ ។

ម៉ារានិងយ៉ូសែបបានភ្ញាក់ផ្អើលពេលឃើញព្រះយេស៊ូវនៅក្នុងវិហារ។ នាងម៉ារាសួរព្រះយេស៊ូវថា៖ «កូនអើយហេតុអ្វីបានជាកូនធ្វើដូច្នេះចំពោះយើង? យើងបានស្វែងរកកូនគ្រប់ទីកន្លែង។ យើងមានការព្រួយបារម្ភខ្លាំងណាស់!" ព្រះយេស៊ូវមានព្រះបន្ទូល ទៅគេថា៖ «ហេតុអ្វីបានជាដើររកខ្ញុំដូច្នេះ? តើអ្នកមិនដឹងទេថាខ្ញុំត្រូវតែនៅកន្លែងដែលព្រះវរបិតាខ្ញុំគង់នៅ? ម៉ារានិងយ៉ូសែបមិនយល់ពីអត្ថន័យរបស់ព្រះយេស៊ូវទេ។ ពួកគេមិនបានគិតអំពីព្រះយេស៊ូវជាបុត្រារបស់ព្រះដ៏ជាព្រះទេ។

ព្រះយេស៊ូវទ្រង់បានត្រឡប់ទៅណាសារ៉ែតជាមួយម៉ារានិងយ៉ូសែប ហើយបានរស់នៅដោយគោរពប្រតិបត្តិស្តាប់បង្គាប់ពួកគេ។ នាងម៉ារាបានចងចាំទុកហេតុការណ៍ទាំងអស់នេះក្នុងចិត្តនាង។ ព្រះយេស៊ូវទ្រង់បានធំធាត់ឡើងទាំងរូបរាងកាយ និងវិញ្ញាណរបស់ទ្រង់។ ទ្រង់បានទទួលពរពីព្រះនិងមនុស្ស ។

**(លូកា ២)**

1.06 **កុមារភាពរបស់ព្រះយេស៊ូវ - ការណែនាំសម្រាប់គ្រូបង្រៀន**

**កំណត់សំគាល់:**

១) ព្រះយេស៊ូវទ្រង់បានធំឡើងជាមួយម៉ារា និងយ៉ូសែបនៅក្រុងណាសារ៉ែត។

២) ជារៀងរាល់ឆ្នាំ តែងមានបុណ្យរំលងនៅក្រុងយេរូសាឡិម។ មនុស្សជាច្រើនបានធ្វើដំណើរដោយថ្មើរជើង អស់រយៈពេលជាច្រើនថ្ងៃ ដើម្បីទៅដល់ក្រុងយេរូសាឡឹម ចូលរួមការប្រារព្ធពិធីបុណ្យនេះ។ ម៉ារា យ៉ូសែបនិងព្រះយេស៊ូវក៏បានធ្វើដំណើរតាមរបៀបនេះ ដើម្បីមកធ្វើបុណ្យរំលងដែរ ។

៣) នៅពេលប្រារព្ធពិធីចប់ មនុស្សទាំងអស់បានចាប់ផ្តើមធ្វើដំណើរត្រឡប់ទៅទីក្រុងរបស់ពួកគេវិញ។ បន្ទាប់ពីធ្វើដំណើរបានមួយថ្ងៃ ម៉ារា និងយ៉ូសែបបានសម្គាល់ថា ព្រះយេស៊ូវមិននៅជាមួយមិត្តភក្តិ ឬសាច់ញាតិរបស់ពួកគេទេ។ ពួកគេបានត្រឡប់ទៅក្រុងយេរូសាឡិមវិញ ដើម្បីទៅរកទ្រង់នៅទីនោះ។

៤) ពួកគេបានរកឃើញព្រះយេស៊ូវនៅក្នុងព្រះវិហារ ស្តាប់ការបង្រៀននិងសួរសំណួរ។ ពួកគ្រូមានការងឿងឆ្ងល់ជាខ្លាំងអំពីរបៀបដែលព្រះយេស៊ូវអាចយល់ពីការបង្រៀនបាន ។ ម៉ារា និងយ៉ូសែបមានការភ្ញាក់ផ្អើលជាខ្លាំងដែលឃើញព្រះយេស៊ូវនៅទីនោះ ហើយបានសួរទ្រង់ថា ហេតុអ្វីបានជាទ្រង់នៅក្រុងយេរូសាឡិម ហើយធ្វើឲ្យពួកគេព្រួយបារម្ភដូច្នេះ?

៥) ព្រះយេស៊ូវបានមានបន្ទូលថា ទ្រង់ត្រូវតែនៅកន្លែងព្រះវរបិតាទ្រង់គង់នៅ។ ប៉ុន្តែព្រះយេស៊ូវទ្រង់បានស្តាប់បង្គាប់ ព្រះអង្គយាងត្រឡប់ទៅណាសារ៉ែតជាមួយពួកគេវិញ។ ទ្រង់ធំធាត់ឡើងហើយពោពេញដោយព្រះពរពីព្រះ។

**សំណួរ:**

១) តើព្រះយេស៊ូវបានធំឡើងនៅក្នុងក្រុងអ្វី?

២) តើម៉ារា យ៉ូសែប និងព្រះយេស៊ូវបានទៅណា ដើម្បីប្រារព្ធពិធីបុណ្យរំលង?

៣) នៅពេលពិធីបានចប់ តើម៉ារា និងយ៉ូសែបបានដើរយូរប៉ុណ្ណាមុនពេលដែលពួកគេដឹងថា ព្រះយេស៊ូវមិននៅជាមួយមិត្តភក្តិ ឬ សាច់ញាតិរបស់ពួកគេ?

៤) តើម៉ារា និងយ៉ូសែប រកឃើញព្រះយេស៊ូវនៅទីណា?

៥) តើព្រះយេស៊ូវកំពុងធ្វើអ្វីនៅក្នុងព្រះវិហារ?

៦) ហេតុអ្វីបានជាព្រះយេស៊ូវនៅក្នុងព្រះវិហារ?

**ចម្លើយ:**

១) ព្រះយេស៊ូវបានធំធាត់ឡើងនៅភូមិណាសារ៉ែត។

២) ម៉ារា យ៉ូសែប និងព្រះយេស៊ូវ ធ្វើដំណើរទៅក្រុងយេរូសាឡឹម ដើម្បីធ្វើបុណ្យរំលង។

៣) ម៉ារានិងយ៉ូសែបបានដើររយៈមួយថ្ងៃ មុនពេលគេដឹងថាព្រះយេស៊ូវមិននៅជាមួយមិត្តភក្តិ ឬសាច់ញាតិរបស់ពួកគេឡើយ។

៤) ម៉ារា និងយ៉ូសែបបានជួបព្រះយេស៊ូវ នៅក្រុងយេរូសាឡិម ហើយនៅក្នុងព្រះវិហារ។

៥) ព្រះយេស៊ូវកំពុងស្តាប់គ្រូបង្រៀន នៅក្នុងព្រះវិហារ ហើយសួរសំណួរពួកគេ។

៦) ព្រះយេស៊ូវទ្រង់បានមានបន្ទូលថា ទ្រង់ត្រូវតែនៅកន្លែងដែលព្រះវរបិតាទ្រង់គង់នៅ។

